ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

04-12-23
F3331

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ ០៥៦ អ.ស.ហ.ប្រក

# ប្រកាស
## ស្តីពី
## ការព្យួរការងារមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

*****

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញប្រកាសលេខ ០០៩ អ.ស.ហ.ប្រក ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃនាយកដ្ឋានក្រោមឱវាទរបស់អង្គភាពសវនកម្មផ្ទៃក្នុង
- ប្រកាសលេខ ០១០ អ.ស.ហ. ប្រ.ក. ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១ ស្តីពីលក្ខន្តិកៈនៃមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញប្រកាសលេខ ០៤៣ អ.ស.ហ.ប្រក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីទទួលស្គាល់មន្ត្រីលក្ខន្តិកៈនៃមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- យោងតាមសំណើរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

## សម្រេច

**ប្រការ១.-**

ត្រូវបានព្យួរការងារលោក **ឌឿន ចណ្ណារិទ្ធិ** ជាមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារដែលបម្រើការងារនៅការិយាល័យសវនកម្មទី៣ នៃនាយកដ្ឋានសវនកម្មទី២ នៃអង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. រយៈពេល ០២ឆ្នាំ ចាប់ពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៥។

**ប្រការ២.-**

បៀវត្សមូលដ្ឋាន និងប្រាក់ឧបត្ថម្ភផ្សេងៗរបស់សាមីខ្លួនត្រូវផ្អាកបើក ចាប់ពីកាលបរិច្ឆេទដូចបានកំណត់ក្នុងប្រការ១ នៃប្រកាសនេះ រហូតដល់មានប្រកាសទទួលស្គាល់ពី អ.ស.ហ. ជាថ្មី តាមការស្នើសុំរបស់សាមីខ្លួន។

**ប្រការ៣.-**

សាមីខ្លួនត្រូវដាក់ពាក្យបន្តព្យួរ ឬសុំចូលបម្រើការងាររបស់ខ្លួនវិញ ឱ្យបាន ២ (ពីរ) ខែ មុនពេលផុតកំណត់នៃរយៈពេលនៃការព្យួរ។ ប្រសិនបើសាមីខ្លួនពុំបានដាក់ពាក្យសុំបន្តព្យួរ ឬសុំចូលបម្រើការងាររបស់ខ្លួនវិញ នៅថ្ងៃចុងក្រោយនៃការព្យួរការងារ ចាត់ទុកថាបោះបង់ចោលការងារ នឹងត្រូវបានលុបឈ្មោះចេញពីមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារចាប់ពីថ្ងៃនោះតទៅ។

**ប្រការ៤.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ប្រធានអង្គភាពសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃអង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ព្រមទាំងសាមីខ្លួនដូចចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ[illegible] ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- អង្គភាពសវនកម្មផ្ទៃក្នុង
- ដូចប្រការ ៤
  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

INTERNAL AUDIT UNIT

**អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**
**អង្គភាពសវនកម្មផ្ទៃក្នុង**
លេខ: ៥៨៥/២៣... អ.ស.ផ.

ចូលថ្ងៃ 15.11.23 ម៉ោង
លេខ 230.5569

ថ្ងៃចន្ទ ១កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ ២០២៣

**សូមគោរពជូន**

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**កម្មវត្ថុ៖** ករណីស្នើសុំការព្យួរការងាររបស់មន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដែលបម្រើការងារនៅអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

**យោង៖**
- ប្រកាសលេខ ០១០ អ.ស.ហ. ប្រ.ក. ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០២១ ស្តីពីលក្ខន្តិកៈនៃមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ប្រកាសលេខ ០៤៣ អ.ស.ហ.ប្រក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ ស្តីពីការទទួលស្គាល់មន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- លិខិតស្នើសុំការព្យួរការងាររបស់លោក ជឿន វណ្ណារិទ្ធិ ចុះថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៣។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា៖ លោក ជឿន វណ្ណារិទ្ធិ ជាមន្ត្រីលក្ខន្តិកៈរបស់ អ.ស.ហ. ដែលបម្រើការងារនៅអង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. បានដាក់លិខិតស្នើសុំព្យួរការងារ នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៣ ដោយមូលហេតុមានធុរៈចាំបាច់បន្ទាន់នៅក្នុងគ្រួសារត្រូវបំពេញ។ អនុលោមតាមប្រកាសស្តីពីលក្ខន្តិកៈនៃមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ការព្យួរការងាររបស់មន្ត្រីត្រូវកំណត់ដោយប្រកាសរបស់ប្រធាន អ.ស.ហ. ដូចនេះ ខ្ញុំសូមគោរពស្នើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** មេត្តាចុះហត្ថលេខាលើប្រកាសស្តីពីការព្យួរការងារមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាសេវាហិរញ្ញវត្ថុមិនមែនធនាគារ (សូមគោរពដ៏ខ្ពង់ខ្ពស់ភ្ជាប់មកជាមួយនូវប្រកាសស្តីពីការព្យួរការងារ) ដោយសេចក្តីអនុគ្រោះបំផុត។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់បំផុត។

សូម **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ

**អង្គភាពសវនកម្មផ្ទៃក្នុង**
**ប្រធាន**

**ឈុន សម្បត្តិ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អង្គភាពសវនកម្មផ្ទៃក្នុង

នាយកដ្ឋានសវនកម្មទី២

លេខ:..១៦៣..២៣អ. ស. ផ./ ស. ក២

**សូមគោរពជូន**

**ឯកឧត្តមប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ.**

**កម្មវត្ថុ÷** សំណើសុំការអនុញ្ញាតឲ្យរការងារនៅអង្គភាពសវនកម្មផ្ទៃក្នុងរយៈពេល ០២ (**ពីរ**) ឆ្នាំ ដោយគិតពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៥ និងគោរពស្នើសុំលិខិតបញ្ជាក់ជាមន្ត្រីនៃអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

**យោង÷** ប្រកាសលេខ ០៤៣ អ. ស. ហ. ប្រក. ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ ស្ដីពីការទទួលស្គាល់មន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជម្រាបជូន**ឯកឧត្តមប្រធាន** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា÷ នាពេលបច្ចុប្បន្ននេះ ខ្ញុំបាទមានធុរៈចាំបាច់បន្ទាន់នៅក្នុងគ្រួសារត្រូវបំពេញ ជាហេតុធ្វើឱ្យខ្ញុំបាទពុំមានពេលវេលាគ្រប់គ្រាន់ក្នុងការបម្រើការងារជូនស្ថាប័ន។ ដើម្បីជៀសវាងផលប៉ះពាល់ដល់ប្រសិទ្ធភាព និងប្រសិទ្ធផលការងារដែលថ្នាក់ដឹកនាំបានប្រគល់ជូន ខ្ញុំបាទសូមគោរពស្នើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមប្រធាន** ព្យួរការងារប្រចាំថ្ងៃរយៈពេល ០២ (ពីរ) ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៣ រហូតដល់ ថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២៥ និងគោរពស្នើសុំ **ឯកឧត្តមប្រធាន** នូវលិខិតបញ្ជាក់ជាមន្ត្រីនៃអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២២ ដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣។

សេចក្ដីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងសម្រេចដោយក្ដីអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

ថ្ងៃចន្ទ ៨ រោច ខែអស្សុជ ឆ្នាំថោះ ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២៣

**ការិយាល័យសវនកម្មទី៣**

**មន្ត្រី**

**ជឿន វណ្ណារិទ្ធិ**